01032938

E320

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 10 / 2014
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់អង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន

១. ក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបើកក្នុងសំណុំរឿង ០០២/០២ កាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ជនជាប់ចោទ នួន ជា និង ខៀវ សំផន បានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា ពួកគេបានបង្គាប់ក្រុមមេធាវីការពារក្តីរបស់ពួកគេរៀងៗខ្លួនធ្វើពហិការមិនចូលរួមកិច្ចដំណើរការនីតិវិធីសវនាការ។ បន្ទាប់មកមេធាវីជាតិ និងមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទនីមួយៗបានចាកចេញពីបន្ទប់សវនាការ។ ក្រុមមេធាវីបានផ្តល់មូលហេតុមួយចំនួនសម្រាប់ការធ្វើពហិការនេះ ដោយរួមទាំងបញ្ហាកង្វះធនធាន (លើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន នៅទំព័រ ៨១ នៃប្រតិចារឹកថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤) និងបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងដែលមិនទាន់ត្រូវបានសម្រេចនៅឡើយ (លើកឡើងដោយក្រុមមេធាវីការពារក្តី នួន ជា នៅទំព័រ ៧៣ នៃប្រតិចារឹកថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ និងលើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន នៅទំព័រ ៧៥-៧៦ នៃប្រតិចារឹកថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤)។

២. ក្នុងបរិបទនៃបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនាពេលបច្ចុប្បន្នដែលបានដាក់ដោយក្រុមមេធាវីការពារក្តីទាំងពីរក្រុម ក្រុមមេធាវីការពារក្តី នួន ជា បានអះអាងថា ដោយយោងលើមាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ចៅក្រមដែលត្រូវគេប្តឹងជំទាស់ ត្រូវដកខ្លួនចេញពីការជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងធ្វើការកត់សម្គាល់ថា កិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្នគឺអនុវត្តតាមវិធាន ៣៤ (៥) នៃវិធានផ្ទៃក្នុង ដែលចែងយ៉ាងច្បាស់ថា ចៅក្រមដែលកំពុងមានបញ្ហា អាចបន្តចូលរួមនៅក្នុងកិច្ចដំណើរ

ការនីតិវិធី ដោយរង់ចាំសេចក្ដីសម្រេចស្ដីពីបណ្ដឹងមិនចិត្ត។ ទោះបីជាបទបញ្ញត្តិទាំងពីរនេះមានភាពខុសគ្នាក៏ដោយ ក៏នៅក្នុងបរិបទនេះ វិធាន៣៤(៥)មានភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិ[1]។ ដូច្នេះហើយ ផ្ទុយស្រឡះទៅនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្ដី ដែលផ្អែកលើការយល់ខុសមួយទៅលើក្របខណ្ឌច្បាប់ ព្រោះគ្មានបទបញ្ញត្តិណាមួយដែលតម្រូវឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធី ហើយក៏មិនអាចយកមកធ្វើជាមូលហេតុដើម្បីធ្វើឱ្យរាំងស្ទះកិច្ចដំណើរការនីតិវិធីសវនាការនេះដែរ។

៣. ដោយយោងលើការវិវត្តទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាថា អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ សម្រាប់កិច្ចប្រជុំរៀបចំសវនាការដើម្បីពិភាក្សាលើបញ្ហាច្បាប់ និងបញ្ហាអនុវត្តជាក់ស្ដែងនានាបន្ទាប់ពីការិយាល័យសហព្រះរាជអាជ្ញាបានដាក់នូវឯកសារនៃកំណត់ហេតុស្ដាប់ចម្លើយថ្មីៗរបស់សាក្សី ក៏ដូចជាធ្វើការពិភាក្សាពីបញ្ហាធនធាន និងបញ្ហាពាក់ព័ន្ធនានា។ នៅក្នុងការប្រាស្រ័យទាក់ទងជាមួយភាគីនានាកាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីទាំងអស់ចូលរួម ហើយក៏បានអញ្ជើញប្រធាន និង/ឬ អនុប្រធានការិយាល័យរដ្ឋបាលមកចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការនេះដែរ (សូមពិនិត្យឧបសម្ព័ន្ធ១)។

៤. ទោះបីជាមានការបង្គាប់ឱ្យចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការដែលពិភាក្សាពីបញ្ហានៃការគ្រប់គ្រងជាជាងសវនាការដេញដោលអំពីខ្លឹមសារនៃសំណុំរឿងក៏ដោយ ក៏មេធាវីការពារក្ដី នួន ជា និង ខៀវ សំផន មិនមានវត្តមាន ឬផ្ដល់ហេតុផលសមស្របសម្រាប់អវត្តមានរបស់ពួកគេដែរ ដែលនេះជាការរំលោភលើការបង្គាប់របស់ អង្គជំនុំជម្រះសាលាដំបូង។

៥. ផ្នែកពាក់ព័ន្ធនៃវិធាន ៣៨ នៃវិធានផ្ទៃក្នុង ចែងថា:

១. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬ បដិសេធ ក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្ដី ឬ ផ្ទុយទៅនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង។

---

[1] សូមមើល រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Seromba,* កថាខណ្ឌ២១ នៃសាលដីកាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា (សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថាតើ គួរតែផ្អាកការជំនុំជម្រះ នៅខណៈដែលបណ្ដឹងមិនចិត្តមិនទាន់ត្រូវបានសម្រេចនៅឡើយ គឺជាការសម្រេចចិត្តដោយឆន្ទានុសិទ្ធិ)។ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Galic,* កថាខណ្ឌ៣៣ នៃសាលដីកាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី។

២. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។

៦. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការប្រព្រឹត្តដូចដែលបានរៀបរាប់ខាងលើគឺជាការធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីសវនាការ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជូនដំណឹងដល់ភាគីនានាថា អនុស្សរណៈនេះគឺជាការព្រមានជាផ្លូវការចំពោះការប្រព្រឹត្តិខុសឆ្គងរបស់មេធាវីជាតិ និងមេធាវីអន្តរជាតិការពារក្តី នួន ជា និង ខៀវ សំផន ដោយអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។

៧. ដើម្បីជៀសវាងការយល់ច្រឡំផ្សេងៗដែលអាចនឹងកើតមាន អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យសហ-មេធាវីការពារក្តី នួន ជា និង ខៀវ សំផន ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ភ្លាមៗនៅពេលដែលពួកគេបញ្ឈប់ការធ្វើពហិការនេះ។

៨. អង្គជំនុំជម្រះមិនទាន់ទទួលបានព័ត៌មានពេញលេញអំពីបញ្ហាកង្វះធនធានដែលក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងនោះទេ (សូមពិនិត្យប្រតិចារឹកថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៨០, ឯកសារ E314/5/1 កថាខណ្ឌ៩ ទំព័រ ១៩-២០) ដោយសារតែមេធាវីការពារក្តីអវត្តមានដោយគ្មានមូលហេតុពីកិច្ចប្រជុំរៀបចំសវនាការ។ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងមានការយល់ដឹងពេញលេញលើស្ថានភាពនេះ អង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើការបង្ហាញពីបញ្ហានេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីនានាមានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការមួយទៀត ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ចាប់ពីម៉ោង ៩.00 នាទីព្រឹកតទៅ។ អង្គជំនុំជម្រះសាលាដំបូងធ្វើការបញ្ជាក់ថា នេះជាឱកាសតែមួយគត់ សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើការពិភាក្សាបញ្ហាធនធានបច្ចុប្បន្នជាមួយអង្គជំនុំជម្រះសាលាដំបូង។

៩. នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ ភាគីនានានឹងត្រូវបានផ្តល់ឱកាសជូនដើម្បីលើកឡើងអំពីសំណើរបស់សហព្រះរាជអាជ្ញាក្នុងការចាត់តាំងមេធាវី *បម្រុង (amici curiae counsel)* ដើម្បីជម្រុញកិច្ចដំណើរការនីតិវិធីសវនាការ។ ឯកសារក្រៅផ្លូវការនៃសំណើសុំនេះ ត្រូវបានចែកជូននៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤។

១០. ដោយយោងលើការវិវត្តទាំងនេះ និងបញ្ហានានាដែលកំពុងតែកើតមាន អង្គជំនុំជម្រះសាលាដំបូងសម្រេចលុបចោលសវនាការដែលត្រូវបានកំណត់កាលបរិច្ឆេទនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់កាលបរិច្ឆេទសវនាការជាថ្មី នៅក្នុងពេលឆាប់ៗនេះ។